**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មាន

## ព័ត៌មានក្រើនរំលឹកស្តីពីការបង្ការករណីពុលស្រា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធាណៈជនទាំងអស់ឲ្យបានជ្រាប ថា កន្លងមក ក្រសួងធ្លាប់បានចេញសេចក្តីប្រកាសព័ត៌មានជម្រាបជូនសាធារណជនទាំងអស់ អំពីការ បង្ការករណីពុលស្រាជាច្រើនលើករួចមកហើយ ក៏ប៉ុន្តែដោយសារនាពេលថ្មីៗនេះ ក្រសួងសុខាភិបាល បាន សង្កេតឃើញថា ករណីពុលស្រាបានកើតឡើងជាបន្តបន្ទាប់នៅតាមសហគមន៍នៃបណ្តាខេត្តមួយចំនួន ដូចជា នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ មានករណីសង្ស័យពុលស្រា សរុបចំនួន ៦២ នាក់ ( ស្លាប់ចំនួន ១៣ នាក់ ) បានកើតឡើង នៅឃុំក្តុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង *ដោយសារពួកគាត់បានពិសាស្រាស ឬស្រាថ្នាំ* **ឯកឧត្តមបណ្ឌិត ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមប្រកាសធ្វើការក្រើនរំលឹក ជូនដល់ប្រជាជនទាំងអស់ ឲ្យមានការប្រុងប្រយ័ត្នការពិសាស្រាដែលបានផលិត ឬបានបិត ដោយមិនមាន លក្ខណៈបច្ចេកទេសត្រឹមត្រូវ និងសូមចូលរួមអនុវត្តនូវវិធានការប្រុងប្រយ័ត្ន រួមទាំងការការពារផ្ទាល់ខ្លួន និង ក្រុមគ្រួសាររបស់ខ្លួន ដើម្បីជៀសផុតពីករណីពុលស្រានេះ។

ក្រសួងសុខាភិបាល សូមជម្រាបជូនសាជាថ្មីថា ករណីពុលស្រា គឺបង្កឡើងដោយសារជាតិមេតាណុលដែលមាននៅក្នុងស្រាលើសពីកម្រិតធម្មតា (០,១៥%) ដែលមានកើតឡើងនៅច្រើនកន្លែងនៅទូទាំងពិភពលោក ដោយសារស្រាដែលផលិតឬបិត នៅតាមមូលដ្ឋានសហគមន៍មិនបានត្រឹមត្រូវតាមក្បួន ខាងបច្ចេកទេស។ ការពុលស្រា បណ្តាលអោយ ស្រវាំង ឬងងឹតភ្នែក សន្លប់ ប្រកាច់ ពិបាកដកដង្ហើម និងអាចវិវត្តទៅស្លាប់បាន។

ពាក់ព័ន្ធនឹងករណីខាងលើ **ឯកឧត្តមបណ្ឌិត ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល មាន ប្រសាសន៍ថា" *ហេតុការណ៍កើតឡើងដោយសង្ស័យថាពុលស្រា ដែលបានមកសម្រាកព្យាបាលនៅ មូលដ្ឋានសុខាភិបាលសាធារណៈ និងមានករណីស្លាប់ក្រោយកើតហេតុ បានកើតឡើងដោយសារ ពួកគាត់បានពិសាស្រាស ឬស្រាថ្នាំ ដែលមានសារជាតិមេតាណុលខ្ពស់ បញ្ជាក់តាមលទ្ធផលបានមក ពីមន្ទីរពិសោធន៍ នាពេលកន្លងមកលើករណីពុលស្រាស ឬស្រាថ្នាំពីពេលមុនៗ។ ដូច្នេះ សូមបងប្អូន*

ប្រជាពលរដ្ឋ បញ្ឈប់ជាបន្ទាន់នូវការពិសារស្រាស ឬស្រាថ្នាំ ដែលផលិតដោយមិនមានបច្ចេកទេសត្រឹមត្រូវ។ បើនៅតែបន្តហូបស្រាស ឬស្រាថ្នាំទាំងនេះទៀតនោះ នឹងបណ្តាលឲ្យប៉ះពាល់ ដល់សុខភាពទៅជាឈឺ ឬអាចបាត់បង់ជីវិត។ ប្រសិនបើបងប្អូនមានបញ្ហាសុខភាព ឬជម្ងឺ សូមប្រញាប់ទៅកាន់មណ្ឌលសុខភាពឬមន្ទីរពេទ្យដែលនៅជិតបំផុត ”។

ហេតុការណ៍សង្ស័យពុលស្រាដែលបានកើតឡើងនៅឃុំក្តុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង នោះ មន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង រួមជាមួយក្រសួងសុខាភិបាល បានចាត់វិធានការណ៍ជាបន្ត បន្ទាប់នៅគ្រប់ទីតាំងនៃហេតុការណ៍ដែលបានកើតឡើង និងធ្វើការតាមដានដោយយកចិត្តទុកដាក់ ដោយបាន៖

- ចុះស្រាវជ្រាវជាបន្តបន្ទាប់ដល់ទីកន្លែងកើតហេតុ និងយកសំណាកស្រាមកធ្វើវិភាគ។
- ជួយសង្គ្រោះ ព្រមទាំងផ្តល់ការពិនិត្យនិងព្យាបាលគ្រប់ករណីសង្ស័យពុលស្រាទាំងអស់ ដោយយកចិត្តទុកដាក់ខ្ពស់បំផុតពីក្រុមគ្រូពេទ្យនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព។
- អប់រំណែនាំប្រជាជននៅតាមភូមិ-ឃុំ ដែលកើតហេតុ ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ដោយអនុវត្តខ្ជាប់ខ្ជួននូវអនាម័យចំណីអាហារឲ្យបានល្អ និងត្រូវបញ្ឈប់ជាបន្ទាន់នូវការពិសារស្រា ដែលផលិត ឬបិតស្រា មិនបានត្រឹមត្រូវតាមក្បួនខ្នាតបច្ចេកទេស។
- សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបិទទីកន្លែងផលិតស្រាស ឬស្រាថ្នាំ ដែលពាក់ព័ន្ធទៅនឹងការសង្ស័យថាធ្វើឲ្យពុលទាំងអស់។
- បន្តតាមដាន និងអប់រំប្រជាជនទូទៅ អំពីអនាម័យចំណីអាហារ ក្នុងការចេះការពារខ្លួន កុំឲ្យមានការពុលស្រា ដោយមានចែកជូននូវសារអប់រំ ជាដើម ។

ក្រសួងសុខាភិបាលនឹងបន្តធ្វើការជូនដំណឹងដល់សាធារណៈជន អំពីការអភិវឌ្ឍន៍នៃបញ្ហាសុខភាពនានាតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះ មានសម្ភារៈអប់រំសុខភាព ដែលអាចទាញយកមកមើលបាន។

<u>សំរាប់ព័ត៌មានបន្ថែមទៀតសូមទាក់ទង:</u>

ក្រសួងសុខាភិបាល តាមរយៈនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លង
លោកវេជ្ជ. លី សូវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

ក្រសួងសុខាភិបាល

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៥ ឆ្នាំ២០១៦